■改編自:新北市教育局多元
文化繪本東南亞篇
□自編

111 年新北市各級學校東南亞語文競賽
團體朗讀文稿東埔寨 國高中 組 A-1

# ខ្ញុំស្រឡាញ់សត្វដំរី

លៃ វាគឺជាកូនដំរីមួយក្បាលដែលវង្វេងផ្លូវ ដែរដើរវិលវល់ក្នុងព្រៃ ពេលតាបានឃើញភ្លាម គាត់ហើយនឹងអ្នកភូមិនាំគ្នា វាយស្គរ ស្រែកទ្រហ បណ្តេញចូល ម្តងបន្តិចៗគ្រប់ទិស។ ពេលវាឈរភ្លឹកភ្លេចខ្លួនដល់ចំកណ្តាល តាយកខ្សែពួរក្រវីជារង្វង់មកធ្វើជាផ្ទាក់ទាក់ចង ។ មុនដំបូងវាកាចខ្លាំងណាស់ មិនអោយខ្ញុំចូលជិតវាទេ ។ បន្ទាប់ពីនេះមកខ្ញុំក៏បានក្លាយជាសំណប់ចិត្តរបស់ដំរីលៃបន្តិចម្តងៗ។

បន្ទាប់មក តាទៅបាត់ វានិងខ្ញុំធំឡើងទៅហើយ វាមានកំលាំងខ្លាំងអស្ចារ្យណាស់ វិធីអូសទាញឈើពូកែណាស់ គ្មាននរណាអាចប្រៀបផ្ទឹមបាន។ បច្ចុប្បន្ននេះព្រៃឈើតិចទៅៗ វាដឹកភ្ញៀវទេសចរណ៍មួយជើងហើយមួយជើងទៀត ដែរដើរតាមផ្លូវដដែ

លៗ ដោយសំលេងស្រែកទ្រហោសើចសប្បាយក្អាកក្អាយ

រហូតក្លាយជាមានមិត្តគ្រប់រូបមកពីប្រទេសនានាគ្រប់ទិសទី ។

លៃ ស្អែកនេះពួកយើងត្រូវទៅចូលរួមពីធីមង្គលការតាមព្រះ

ពុទ្ធសាសនា។ ដូច្នេះថ្ងៃនេះងូតទឹកដុសលាងស្រស់ស្អាតជា

ពិសេសឲអារម្មណ៍រីករាយស្រស់ថ្លា ។ ពេលព្រឹកព្រលឹម ខ្ញុំ

រវល់រៀបចំតែងខ្លួនអោយលៃ ។ ដល់វេលាពជ័យ អ្នកគ្រប់គ្នា

ផ្តោតអារម្មណ៍ទៅលើអលង្ការរៀបចំបំពាក់លើក្បាលខ្នង និង

កងជើងដ៏មានតំលៃ ដែលស្អាតចាំងភ្លឺភ្នែក !

ថ្ងៃនេះគឺជាថ្ងៃសប្បាយរីករាយបំផុត ។

លៃ ខ្ញុំស្រលាញ់ឯង។